# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំព្រះករុណាខ្ញុំបាទ **ប៉ាំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមការងារខេត្តក្រចេះ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅប្រគេនព្រះថេរានុថេរៈ និងជូនចំពោះសម្ដេច ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនពុទ្ធបរិស័ទ និងញាតិមិត្តជិតឆ្ងាយដែលមានសទ្ធាជ្រះថ្លាចូលរួមចាប់មគ្គផលបុណ្យកឋិនទានរបស់ក្រសួងមុខងារសាធារណៈ និងក្រុមការងារចុះជួយមូលដ្ឋានខេត្តក្រចេះ ដើម្បីដង្ហែទៅកាន់វត្តទាំង១៧២ក្នុងខេត្តក្រចេះ កាលពីថ្ងៃសៅរ៍ ១កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០។

បច្ច័យសរុបរបស់អង្គកឋិនទានចំនួន ៤០០លានរៀល ត្រូវបានបែងចែកជូនក្រុមការងារស្រុក ក្រុងទាំង៦ ដើម្បីចាត់ចែងដង្ហែទៅវេរប្រគេនវត្តនីមួយៗរួចរាល់អស់ហើយ។

កាយវិការដ៏ជាកុសលកម្មពោរពេញដោយសមានចិត្តនៃសាមគ្គីភាពនេះគឺបានរួមចំណែកដ៏ថ្លៃថ្លាក្នុងការលើកស្ទួយព្រះពុទ្ធសាសនាដើម្បីជាគុណប្រយោជន៍ក្នុងការថែរក្សាសីលធម៌ដ៏ប្រពៃរបស់សង្គមជាតិ ការកសាងសមិទ្ធផលនានាតាមវត្តអារាម និងជាការឧទ្ទិសកុសលដល់បុព្វការីជនទាំងឡាយដែលមានសគុណចំពោះគ្រួសារនិងសង្គមជាតិ។

ខ្ញុំព្រះករុណាខ្ញុំបាទ សូមបួងសួងដល់គុណព្រះរតនត្រៃ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយបីបាច់ថែរក្សាព្រះថេរានុថេរៈ សម្ដេច ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនពុទ្ធបរិស័ទ និងញាតិមិត្តជិតឆ្ងាយទាំងអស់ សូមប្រកបដោយសេចក្ដីសុខសេចក្ដីចម្រើនគ្រប់ប្រការ និងទទួលបាននូវអានិសង្សនិងមនុញ្ញផលដែលកើតឡើងពីកឋិនទាននេះទៅតាមសទ្ធាជ្រះថ្លារៀងៗខ្លួន ព្រមទាំងទទួលបានពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។